DEVELOPMENTAL DISABILITIES ADMINISTRATION

# ការជូនដំណឹងការផុតកំណត់សិទ្ធិអាចទទួលបាននៅអាយុដប់ (10) ឆ្នាំ

# Notification of Age Ten (10) Eligibility Expiration

ឈ្មោះ និងអាសយដ្ឋានអ្នកជម្ងឺ

ឈ្មោះ និងអាសយដ្ឋានអ្នកតំណាងអ្នកជម្ងឺ

កូនរបស់អ្នកជាអ្នកជម្ងឺជាមួយរដ្ឋបាលអភិវឌ្ឍន៍ពិការភាព (DDA) ។ សិទ្ធិអាចទទួលបានជាមួយ DDA របស់កូនអ្នកផុតកំណត់នៅថ្ងៃកំណើតឆ្នាំទីដប់របស់គេ ។ ដើម្បីឲ្យកូនអ្នកបន្តសិទ្ធិអាចទទួលបានសម្រាប់ DDA អ្នកត្រូវតែដាក់ពាក្យម្តងទៀតមុនកូនអ្នកអាយុដប់ឆ្នាំ ។ កូនរបស់អ្នកត្រូវបានកំណត់ម្តងទៀតពីសិទ្ធិអាចទទួលបានក្រោមស្ថានខាងក្រោម ៖

អន់បញ្ញា វិបត្តិខួរក្បាលដោយសារការប៉ះទង្គិច ជម្ងឺឆ្កួតជ្រូក ជម្ងឺអូទីស៊ីម ទាក់ទងនឹងសសៃប្រសាទឬស្ថាន ភាពផ្សេងទៀតដែលស្រដៀងនឹងអន់បញ្ញា ។

ពួកយើងបានភ្ជាប់មកជាមួយ*តារាងឯកសារដែលតម្រូវឲ្យមាន* ដើម្បីឲ្យអ្នកដឹងពីអ្វីដែលត្រូវការដើម្បីធ្វើការកំណត់ឡើងវិញ ។

របៀបដាក់ពាក្យម្តងទៀត ៖

ទាក់ទងបុគ្គលិក DDA ការចូល និងសិទ្ធិអាចទទួលបានយ៉ាងហោចណាស់ 90 ថ្ងៃមុនថ្ងៃកំណើតឆ្នាំទីដប់របស់កូនអ្នកដើម្បីស្នើសុំសំណុំពាក្យសុំម្តងទៀត ។ អ្នកអាចធ្វើវាដោយលាយលក្ខអក្សរ ឬដោយទូរស័ព្ទតាមលេខដែលមានខាងក្រោម ។ សំណុំពាក្យសុំនឹងត្រូវផ្ញើឲ្យអ្នក ។ អ្នកក៏អាចទទួលបានឯកសារពាក្យសុំតាមអ៊ីនធើណេតដោយចូលទៅ

https://www.dshs.wa.gov/dda/consumers-and-families/eligibility ។

ចុះបើខ្ញុំមិនដាក់ពាក្យម្តងទៀត?

បើអ្នកមិនស្នើសុំសំណុំពាក្យសុំម្តងទៀត ឬបើអ្នកមិនបញ្ជូនពាក្យសុំមកវិញយ៉ាងហោចណាស់ 60 ថ្ងៃមុនថ្ងៃកំណើតឆ្នាំទីដប់របស់កូនអ្នក សិទ្ធិអាចទទួលបានជាមួយ DDA របស់កូនអ្នកនឹងផុតកំណត់នៅថ្ងៃកំណើតឆ្នាំទីដប់របស់គេ ។ បើកូនអ្នកទទួលសេវាកម្មបង់ប្រាក់ជាមួយ DDA សេវាកម្មនេះនឹងបញ្ចប់នៅថ្ងៃកំណើតឆ្នាំទីដប់របស់គេ ។

ការផុតកំណត់នៃសិទ្ធិអាចទទួលបាន **DDA** នឹងមិនប៉ះពាល់ដល់ការចូលរួមក្នុងកម្មវិធីការអប់រំពិសេស ឬសិទ្ធិអាចទទួលបាន **SSI eligibility** ។ ឬវានឹងមិនប៉ះពាល់សេវាកម្ម **DSHS** ផ្សេងទៀតដែលអ្នកកំពុងទទួល ដូចជា **Medicaid TANF** ឬតែមអាហារ ។

សូមឆ្លើយតបឲ្យបានឆាប់ <u>ប៉ុន្តែយ៉ាងហោចណាស់ 90 ថ្ងៃមុនថ្ងៃកំណើតឆ្នាំទីដប់របស់កូនអ្នក</u> ។ បើពួកយើងមិនបានឮពីអ្នកទេ ពួកយើងនឹងសន្មត់ថាអ្នកមិនចង់បន្តសិទ្ធិអាចទទួលបានជាមួយ DDA របស់កូនអ្នកទេ ។ គ្មានឯកសារត្រឹមត្រូវនៃស្ថានភាពសិទ្ធិអាចទទួលបានដោយអាយុដប់ឆ្នាំ សិទ្ធិអាចទទួលបានជាមួយ DDA និងសេវាកម្ម DDA របស់កូនអ្នកនឹងផុតកំណត់នៅថ្ងៃកំណើតឆ្នាំទីដប់ (10) របស់គេ ។

បើអ្នកមានសំណួរ ឬចង់ស្នើសុំសំណុំពាក្យសុំ សូមទាក់ទង ៖

| ឈ្មោះ | លេខទូរស័ព្ទ | អាសយដ្ឋានអ៊ីម៉ែល |
|---|---|---|

ច្បាប់ចម្លងនៃវិន័យរដ្ឋដែលគ្រប់គ្រងសិទ្ធិអាចទទួលបាន (WAC 388-823) អាចទទួលបានបើមានការស្នើសុំ ឬតាមអ៊ីនធើណេត https://www.dshs.wa.gov/dda/consumers-and-families/eligibility ។

ភ្ជាប់ជូន ៖ តារាងឯកសារដែលតម្រូវឲ្យមាន

ចម្លងជូន ៖ ឯកសារអ្នកជម្ងឺ

អ្នកតំណាងស្របច្បាប់

តារាងឯកសារដែលតម្រូវឲ្យមាន

| ស្ថានភាពពិការភាព | អាយុ | រោគវិនិច្ឆ័យ | អ្នកធ្វើរោគវិនិច្ឆ័យ | កំណត់ត្រាផ្សេងទៀត |
|---|---|---|---|---|
| អន់បញ្ញា | អាយុ 4 ឆ្នាំ និងច្រើនជាងនេះ | អន់បញ្ញា<br>(ពីមុនការលូតលាស់យឺតយ៉ាវផ្នែកសតិបញ្ញា) | អ្នកចិត្តសាស្រ្តដែលមានអាជ្ញាប័ណ្ណ សាលាចិត្តសាស្រ្តដែលបញ្ជាក់ត្រឹមត្រូវរដ្ឋវ៉ាស៊ីនតោន ឬសាលាចិត្តសាស្រ្តផ្សេងទៀត ដែលបញ្ជាក់ត្រឹមត្រូវដោយសមាគមជាតិនៃសាលាចិត្តសាស្រ្ត | របាយការណ៍ចិត្តសាស្រ្តពេញលេញដែលរាប់បញ្ចូលទាំងជញ្ជីងពិន្ទុ IQ ពេញលើសពីគម្លាតស្តង់ដាពីរដងក្រោមមធ្យម និងពិន្ទុតេស្តជំនាញសម្របខ្លួនលើសពីគម្លាតស្តង់ដាពីរដងក្រោមមធ្យម ។ |
| វិបត្តិខួរក្បាលដោយសារការប៉ះទង្គិច | អាយុ 4 ឆ្នាំ និងច្រើនជាងនេះ | វិបត្តិខួរក្បាលដោយសារការប៉ះ ទង្គិច<br>រោគខ្វិន<br>ការស្លាប់មួយចំហៀងខ្លួន<br>ភាពខ្វិននៃផ្នែកដូចគ្នាលើចំហៀងទាំងពីរនៃដងខ្លួន (ដូចជាដៃទាំង ពីរ) | គ្រូពេទ្យដែលមានអាជ្ញាប័ណ្ណ | ការចាប់ផ្តើមមុនអាយុ 3 ឆ្នាំ និងព័ត៌មានគាំទ្រតម្រូវការជំនួយផ្នែករាងកាយផ្ទាល់ប្រចាំថ្ងៃក្នុងពីរ ឬច្រើនផ្នែក (ចូលបង្គន់ ងូតទឹក ហូបអាហារ ស្លៀកពាក់ ធ្វើដំណើរ ឬទំនាក់ទំនង) ។ |
| ជម្ងឺឆ្កួតជ្រូក | អាយុ 4 ឆ្នាំ និងច្រើនជាងនេះ | ជម្ងឺឆ្កួតជ្រូក ឬជម្ងឺប្រកាច់ | ក្រុមប្រឹក្សាគ្រូពេទ្យផ្នែកសសៃប្រសាទដែលបញ្ជាក់ត្រឹមត្រូវ | រោគវិនិច្ឆ័យផ្អែកលើប្រវត្តិសុខភាព និងការធ្វើតេសសសៃប្រសាទ ការបញ្ជាក់ពីគ្រូពេទ្យ ឬគ្រូពេទ្យផ្នែកសសៃប្រសាទនៃការប្រកាច់ដែលមិនអាចគ្រប់គ្រងបាន និងកើតឡើងបន្តបន្ទាប់ និងតេស្តជំនាញសម្របខ្លួនបង្ហាញការកម្រិតសំខាន់ក្នុងមុខងារសម្របខ្លួនលើសពីគម្លាតស្តង់ដាពីរដងក្រោមមធ្យម ។ |
| ជម្ងឺអូទីសឹម (Autism)<br>(ក្នុងមួយ DSM-IV) | អាយុ 4 ឆ្នាំ និងច្រើនជាងនេះ | ជម្ងឺអូទីសឹម (Autism) ឬ Autistic Disorder<br>299.00, DSM-IV-TR | គ្រូពេទ្យចិត្តសាស្រ្តដែលមានអាជ្ញាប័ណ្ណ គិលានុប្បដ្ឋាយិកាកម្រិតខ្ពស់ដែលបានចុះឈ្មោះ (ARNP) ដែលទាក់ទងនឹងជម្ងឺអូទីសឹម (Autism) ឬមជ្ឈមណ្ឌលអភិវឌ្ឍន៍ ឬក្រុមប្រឹក្សាដែលបញ្ជាក់ត្រឹមត្រូវ ៖ គ្រូពេទ្យផ្នែកសសៃប្រសាទ ផ្នែកវិកលចរិត ឬគ្រូពេទ្យផ្នែកអភិវឌ្ឍ និងឥរិយាបថកុមារ | ការវាយតម្លៃពេញលេញក្នុង DSM-IV ដែលបំពេញលក្ខខណ្ឌរោគវិនិច្ឆ័យទាំងអស់ ភស្តុតាងនៃការយឺតយ៉ាវ ឬមុខងារមិនធម្មតាមុនអាយុ 3 ឆ្នាំក្នុងសង្គម ភាសា ជំនាញទំនាក់ទំនង ឬសញ្ញាតំណាង ឬការលេងដោយស្រមើស្រមៃ និងតេស្តជំនាញសម្របខ្លួន បង្ហាញការកម្រិតសំខាន់ក្នុងមុខងារសម្របខ្លួនលើសពីគម្លាតស្តង់ដាពីរដងក្រោមមធ្យម ។ |
| ជម្ងឺ Autism Spectrum Disorder<br>(ក្នុងមួយ DSM-V) | អាយុ 4 ឆ្នាំ និងច្រើនជាងនេះ | Autism Spectrum Disorder 299.00<br>DSM-V រាប់បញ្ចូលទាំងធ្ងន់ធ្ងរកម្រិត 2 ឬ 3 ក្នុងជួរទាំងពីរ | គ្រូពេទ្យចិត្តសាស្រ្តដែលមានអាជ្ញាប័ណ្ណ គិលានុប្បដ្ឋាយិកាកម្រិតខ្ពស់ដែលបានចុះឈ្មោះ (ARNP) ដែលទាក់ទងនឹងជម្ងឺ អូទីសឹម (Autism) ឬមជ្ឈមណ្ឌលអភិវឌ្ឍន៍ ឬក្រុមប្រឹក្សា ដែលបញ្ជាក់ត្រឹមត្រូវ ៖ គ្រូពេទ្យផ្នែកសសៃប្រសាទ ផ្នែកវិកល ចរិត ឬគ្រូពេទ្យផ្នែកអភិវឌ្ឍ និងឥរិយាបថកុមារ | ការវាយតម្លៃពេញលេញក្នុង DSM-V ដែលបំពេញលក្ខខណ្ឌរោគវិនិច្ឆ័យទាំងអស់ ភស្តុតាងនៃការយឺតយ៉ាវ ឬមុខងារមិនធម្មតាមុនអាយុ 3 ឆ្នាំក្នុងសង្គម ភាសា ជំនាញទំនាក់ទំនង ឬសញ្ញាតំណាង ឬការលេងដោយស្រមើស្រមៃ និងតេស្តជំនាញសម្របខ្លួន បង្ហាញការកម្រិតសំខាន់ក្នុង មុខងារសម្របខ្លួនលើសពីគម្លាតស្តង់ដាពីរដង និង FSIQ គម្លាតស្តង់ដាមួយ ឬច្រើនក្រោម មធ្យម – ឬ – បំពេញលក្ខខណ្ឌទាំងអស់សម្រាប់ Autistic Disorder 299.00, DSM-IV ។ |
| ទាក់ទងនឹងសសៃប្រសាទឬស្ថានភាពផ្សេងទៀតដែលស្រដៀងនឹងអន់បញ្ញា | អាយុ 4 ឆ្នាំ និងច្រើនជាងនេះ | វិបត្តិទាក់ទងនឹងសសៃប្រសាទ ឬក្រូម៉ូសូមដែលបង្កឲ្យអន់ថយបញ្ញា និងជំនាញសម្របខ្លួន | គ្រូពេទ្យដែលមានអាជ្ញាប័ណ្ណ | ជញ្ជីងពិន្ទុ IQ ពេញលើសពីគម្លាតស្តង់ដា1.5 ដងក្រោមមធ្យម តេស្តជំនាញសម្របខ្លួនបង្ហាញ ការកម្រិតសំខាន់ក្នុងមុខងារសម្របខ្លួនលើសពីគម្លាតស្តង់ដាពីរដងក្រោមមធ្យម ។ |
| ចំណាំ ៖ បែបបទនេះគឺជាការណែនាំទូទៅតែប៉ុណ្ណោះ ហើយ **DDA** អាចតម្រូវឲ្យមានព័ត៌មាន ឬការវាយតម្លៃបន្ថែម ។ ឯកសារនេះគឺជាជំហានទីមួយក្នុងការកំណត់សិទ្ធិអាចទទួលបាន ។ សិទ្ធិអាចទទួលបាន **DDA** ត្រូវបានកំណត់ក្នុង **WAC** ជំពូក **388-823** ។ | | | | |